# ១៥.ព្រេងទាក់ទងនឹងទៀនកាលនៅពេលមានមនុស្សស្លាប់

ចាស់ៗ បុរាណនិយាយតៗ គ្នាមកថា កាលនោះ មានបុរសម្នាក់ជាអ្នកត្រឹមត្រូវល្អណាស់ បើទៅទីប្រជុំចំណោមឯណា គេតែងរាប់រក ទុកជាមនុស្សមានប្រាជ្ញា ជាអ្នកដឹងខុសត្រូវ-ទាបខ្ពស់ យល់គុណយល់ទោស ហើយជាមនុស្សសុចរិត ។ អ្នកនៅភូមិផងរបងជាមួយ បើមានការអ្វីធំដុំ តែងទៅអញ្ជើញបុរសនោះមកជាប្រធាន ដើម្បីសួរយោបល់ ឬដើម្បីឲ្យជួយអារកាត់រឿងដែលជាប់ជំពាក់ស្មុគស្មាញ ។

ថ្ងៃមួយ ក្នុងរដូវប្រាំង (ខែផល្គុន-ចេត្រ) មាណពនោះបបួលបុរសពីរនាក់ទៀត ដែលនៅផ្ទះក្បែរគ្នាថា "បងអើយ ! ខែនេះ យើងទំនេរ នៅផ្ទះ ស៊ីបាយហើយដើរត្រែតត្រត ធ្វើអ្វី រវល់តែឲ្យប្រពន្ធបម្រើ បើយើងនាំគ្នាទៅរកឃ្មុំ យកក្រមួន និងទឹកវាលក់ ប្រហែលជាមានប្រយោជន៍ជាង គ្រាន់បានលុយកាក់ទិញខោអាវស្លៀកពាក់ និងប្រដាប់ប្រដាប្រើប្រាស់ខ្លះ សោះរវល់លក់ស្រូវជង្រុកចាយ" ។ បុរសទាំងពីរនាក់នោះ គឺស្រុះស្រួលសុខចិត្តទៅជាមួយគ្នា តែបណ្ដាអ្នកទាំងពីរនោះ អ្នកមួយជាមនុស្សចេះស្ដាប់បង្គាប់ ឯអ្នកមួយទៀត ជាមនុស្សរបឹងរឹងរូសមិនសូវចេះស្ដាប់ មិនសូវចេះគ្រងគ្រាប់ពាក្យប្រៀនប្រដៅទេ ។

លុះដើរទៅដល់ព្រៃ ឃើញខ្ទមអ្នកតាមួយ ដែលពួកថ្មើរព្រៃតែងបូជា ដើម្បីសុំបើកព្រៃរួចទើបចូលទៅ ។ មកដល់ជិតកន្លែងអ្នកតានោះ ទើបអ្នកទាំង ៣នាក់ នាំគ្នាធ្វើជំរំឈប់សម្រាកបន្តិចសិន យកកម្លាំងនឹងដើរទៅមុខទៀត ។ ក្នុងថ្ងៃនោះ គេរកបានឃ្មុំមួយសំបុកមានក្រមួន ១២ តម្លឹង ហើយក៏ត្រឡប់មកជំរំវិញ នាំគ្នាដាំបាយដុតត្រីបរិភោគ ។ តែមុននឹងបរិភោគ គេចាប់បាយ និងត្រីខ្លះ ដាក់លើស្លឹកឈើថ្វាយអ្នកតា សុំសេចក្ដីសុខសប្បាយ និងសុំឲ្យទៅរកឃ្មុំបានប្រទះដូចសេចក្ដីប្រាថ្នា ។ ឯបុរសម្នាក់ដែលជាអ្នករឹងរូសនោះ ឃើញអ្នកពីរនាក់សែនអ្នកតា ក៏នឹកក្នាញ់ក្នុងចិត្ត តែមិនចេញស្ដី ។ លុះព្រឹកឡើង មុននឹងចេញទៅរកឃ្មុំទៀត គេនាំគ្នាដាំបាយស៊ី ហើយចាប់បាយបេះត្រីដាក់ថ្វាយអ្នកតាដូចថ្ងៃមុនទៀត ។ បុរសរឹងរូស ទើសចិត្តណាស់ទ្រាំអត់ពុំបានក៏វែធសម្ដីគំពោះទ្រគោះថា "មិនដឹងជាថ្វាយអ្វីក៏ថ្វាយម្ល៉េះទេ! ត្រីតិចហើយដណ្ដើមបេះយកទៅដាក់ចោលទៀត តើដាក់ឲ្យអាណាស៊ី!" ថាហើយ ក៏ងើបដើរទៅយកបាយ និងត្រីរុកបញ្ចុកមាត់អ្នកតា ហើយនិយាយបែបចង់បញ្ឆោះឲ្យអ្នកដែលដាក់ថ្វាយនោះផងថា "ហឺ ស៊ីទៅអ្នកតា! ពីមុនថាគេមិនដាក់ឲ្យដល់មាត់ឥឡូវអញដាក់ដល់មាត់ហើយ ម្ដេចក៏មិនស៊ីទៅ ឃើញទុកឲ្យតែស្រមោចជញ្ជូនលាន់ ម្ដងនេះ តែមិនស៊ីឲ្យអញឃើញផងទេ ក្រោយៗ អញលែងឲ្យទៀតហើយ កុំសង្ឃឹម !" ។ អ្នកពីរនាក់ទៀត ឃើញបុរសនោះធ្វើការមិនគប្បី ក៏នៅស្ងៀម រួចបបួលគ្នាចេញដំណើរទៅ ។ ក្នុងថ្ងៃនោះ គ្មានរកឃ្មុំបានមួយសំបុកសោះ ព្រោះបុរសរឹងរូសនោះ រវល់តែចុកពោះរមួលខ្លួន ដើរមិនរួច ទាល់តែសែង រហូតមកដល់ជំរំវិញ ។ មកដល់ហើយនាំគ្នាធ្វើដូចម្ដេច ក៏ជំងឺនោះមិនស្រាន្ត ។ លុះដល់ពេលកម្លាំងកាន់តែតិចទៅ បុរសឈឺនោះ និយាយនឹងសំឡាញ់ទាំងពីរថា "ចូរឯងចែកក្រមួនឲ្យអញមួយភាគផង ត្បិតអញក៏បានទៅរកជាមួយឯងដែរ" ។ បុរសពីរនាក់ឆ្លើយថា "ឯងចង់បានក្រមួនយកមកធ្វើអ្វី ! បើឯងជិតស្លាប់ទៅហើយយ៉ាងនេះ" ។ បុរសឈឺនោះឆ្លើយវិញថា "អញយកទៅបាន ឲ្យតែឯងចែកមក ឆាប់ឡើង! បើឯងមិនឲ្យអញទេ តើអញបានអ្វីបំភ្លឺផ្លូវសម្រាប់ដើរចេញពីព្រៃនេះរួច" ។

ឮដូច្នោះ បុរសសំឡាញ់ទាំងពីរនាក់ ក៏នាំគ្នាថ្លឹងក្រមួនចែកជាបីភាគស្មើគ្នា ហើយយកស្លឹកឫស្សីងាប់ប្រវែងមួយបង្គុយលលក2 មកធ្វើជាប្រឆេះ ហើយយកក្រមួនមួយចំណែកទម្ងន់ប្រហែលជាបួនតម្លឹងតាមស្មានមកលៃជាបួនភាគ យកបីភាគលញ់ធ្វើជាទៀនគោល ។ ក្រមួននៅសល់មួយភាគទៀត គេយកស្លឹកត្រែងស្ងួត មកធ្វើជាប្រឆេះ លញ់ទៀនរាយបួនទៀត ហើយកាច់មែកឈើមកដាក់គងលើមាត់ត្រឡោកទឹក ដែលយកទៅតាមខ្លួន យកទៀនធំបិទនឹងឈើនោះ ដើម្បីកុំឲ្យស្រក់ក្រមួនចោលទៅដី ហើយយកទៀនរាយបួនទៀត បិទនៅមាត់ត្រឡោក ។ លុះអុចទៀនរួច ក៏ឱននិយាយដាក់ត្រចៀកបុរសឈឺថា "នែសំឡាញ់ ! ចំណែកក្រមួនឯង អញធ្វើជាទៀនអុជឲ្យឯងហើយ ចូរឯងទទួលយកទៅតាមខ្លួន គ្រាន់ជាពន្លឺផ្លូវចេញពីព្រៃនេះទៅចុះ !" ។ បុរសឈឺទទួលថា "អឺ !" ហើយក៏ដាច់ខ្យល់ស្លាប់ទៅ ។

បុរសជាមិត្រ ក៏នាំគ្នារកឧសភ្លើងមកដុតខ្មោចនោះ ហើយនាំគ្នាវេចខ្ចប់ធាតុយកមកឲ្យប្រពន្ធ ដោយប្រាប់តាមដំណើរ តាំងពីរឿងឈឺ ដល់រឿងចែកក្រមួន ។ តែមកដល់ត្រង់នេះ ប្រពន្ធនៃសពមិនព្រម ដោយអាងថា "ប្ដីខ្លួនស្លាប់ទៅហើយ តើអាចយកក្រមួនទៅផងម្ដេចបាន ?" ។ បុរសសំឡាញ់ទាំងពីរនាក់ពន្យល់យ៉ាងដូចម្ដេច នាងនោះ ក៏នៅតែមិនព្រម ទទូចតែយកចំណែកក្រមួន តាំងពីថ្ងៃរហូតដល់យប់ ទាល់តែនាំគ្នាទៅដេករៀងខ្លួនទៅ ។

និយាយពីប្រពន្ធបុរសស្លាប់ លុះដេកលក់ទៅ ក៏យល់សប្តិឃើញប្ដី កាន់ទៀនដើរចូលមក ។ នាងក៏ស្រែកទាំងអរផងថា "អ្នកអើយ ! គេមកប្រាប់ខ្ញុំថា អ្នកឯងស្លាប់ទៅហើយ ថែមទាំងបានចែកក្រមួនឲ្យទៅអ្នកផងឥឡូវ មានស្លាប់ឯណា ! អ្នកមកវិញហើយតើ !" ។ ឯខ្មោចនោះ ឆ្លើយមកវិញថា "អញស្លាប់មែន, ហើយអញបានក្រមួនដែលគេចែកឲ្យនោះ ធ្វើជាទៀនអុជរកផ្លូវចេញមកផ្ទះ កុំអីមិនដឹងជាវង្វេងទៅឆ្ងាយឯណាទេ !" ។ ប្រពន្ធឮដូច្នោះ ក៏ស្ទុះទៅស្រវាឱបប្ដី ភ្ញាក់ទាំងខ្លួនឡើង ទើបដឹងច្បាស់ថាខ្លួនយល់សប្តិ ។ លុះព្រឹកឡើង ក៏ទៅប្រាប់បុរសទាំងពីរតាមដំណើរយល់សប្តិ ហើយក៏ឈប់លែងឈ្លោះប្រកាន់ទៀតទៅ ។

អ្នកស្រុក ដឹងរឿងដូច្នោះ ក៏ប្រកាន់ជឿថា "បើមនុស្សណាជិតស្លាប់, គេត្រូវតែធ្វើទានកាលអុជឲ្យ ដើម្បីឲ្យខ្មោចនោះបានពន្លឺសម្រាប់បំភ្លឺផ្លូវដើរទៅរកឋានសុខ" ។